ឃ ការថែរក្សាជាពិសេស ឬការបង់ថ្លៃ និងការចំណាយលើរទេះរុញ សួតសិប្បនិម្មិត ជើងសិប្បនិម្មិត ទម្រឈើច្រត់ និងរបស់របរផ្សេងទៀត ឬឧបករណ៍ពេទ្យ លើកលែងតែការជួលឧបករណ៍ ឬសម្ភារៈទាំងនោះអំឡុងពេលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ។

ង ជំងឺសរសៃប្រសាទ ឬបញ្ហាខួរក្បាល ជំងឺអេដស៍ ជំងឺសង្គម ជំងឺដែលមានពីកំណើត។

## ផ្នែកទី ៣៖ ការខាតបង់លើប្រាក់កក់ និងការបង់ថ្លៃលើការលុបចោលការធ្វើដំណើរ

ក ៣៥ដុល្លារ ដំបូងលើរាល់ការទាមទារសំណងនីមួយៗ។

ខ ដោយផ្ទាល់ ឬដោយប្រយោលពីកិច្ចការជំនួញរបស់លោកអ្នក កាតព្វកិច្ច ឬកិច្ចសន្យាហិរញ្ញវត្ថុ ឬរបស់អ្នករួមដំណើរជាមួយអ្នក ឬពីស្ថានភាពហិរញ្ញវត្ថុណាក៏ដោយ។

គ ដោយផ្ទាល់ ឬដោយប្រយោល ពីការមិនពេញចិត្តក្នុងការធ្វើដំណើរ ឬអ្នកដែលអ្នករួមដំណើរជាមួយ។

ឃ ដោយផ្ទាល់ ឬដោយប្រយោលពីការខកខានមិនបានចាត់វិធានការភ្លាមៗដើម្បីជូនជាដំណឹងដល់ភ្នាក់ងារទេសចរណ៍ ឬអ្នករៀបចំដំណើរកម្សាន្ត ឬអ្នកផ្តល់មធ្យោបាយធ្វើដំណើរ ឬការស្នាក់នៅ ប្រសិនបើរកឃើញថាវាចាំបាច់ដើម្បីលុបចោល ឬបន្ថយគម្រោងធ្វើដំណើរ។

ង ពីការពរពោះ ឬការសម្រាលកូន។

ច ពីការពន្យារពេលដោយអ្នកដឹកជញ្ជូន លើកលែងតែមានកូដកម្ម។

ឆ ពីការក្ស័យធន ឬការព្រងើយកន្តើយ ឬកំហុសរបស់ភ្នាក់ងារ ឬភ្នាក់ងារធ្វើដំណើរ ឬអ្នកដឹកនាំក្រុមទេសចរណ៍។

ជ ការលុបចោលការធ្វើដំណើរតាមការស្នើសុំពីប្រធាន ប្តី/ប្រពន្ធ ឪពុកម្តាយ។

ឈ ដោយផ្ទាល់ ឬដោយប្រយោលពីសកម្មភាពល្មើសច្បាប់ ឬបណ្តឹងព្រហ្មទណ្ឌ ឬពីនរណាម្នាក់ដែលការធ្វើដំណើរផ្អែកលើ លើកលែងតែការចូលរួមជាសាក្សីនៅឯតុលាការតាមដីកាកោះហៅ។

ញ ដោយផ្ទាល់ ឬដោយប្រយោលពី បញ្ញត្តិ និងច្បាប់របស់រដ្ឋាភិបាល។

## ផ្នែកទី ៤៖ ការបាត់បង់ប្រាក់កាសផ្ទាល់ខ្លួន

ក ៣៥ដុល្លារ ដំបូងសម្រាប់រាល់ការទាមទារសំណងមួយលើក។

ខ ការបាត់បង់ដែលមិនបានរាយកាណ៍ទៅឱ្យប៉ូលីសក្នុងរយៈពេល ២៤ម៉ោង ហើយបានទទួលរបាយការណ៍ពីប៉ូលីស។

## ផ្នែកទី ៥៖ ទំនួលខុសត្រូវផ្ទាល់ខ្លួន

ក រាល់យានយន្តគ្រប់ប្រភេទ ដូចជា ម៉ូតូ យន្តហោះ ឬកាណូត។

ខ វិជ្ជាជីវៈ អាជីវកម្ម ពាណិជ្ជកម្មរបស់អ្នកធានា។

គ រាល់ការធានា និងកិច្ចព្រមព្រៀង លើកលែងតែទំនួលខុសត្រូវអាចកើតមានឡើង ប្រសិនបើគ្មានកិច្ចព្រមព្រៀង ឬការធានានោះ។

ឃ ការរងរបួសដល់ស្លាប់ ឬធ្លាក់ខ្លួនឈឺ ឬការបាត់បង់ ឬខូចខាតទ្រព្យសម្បត្តិរបស់គ្រួសារអ្នកធានា ដែលកំពុងស្នាក់នៅជាធម្មតាជាមួយអ្នកធានា ឬអ្នកធានាកំពុងស្នាក់នៅជាមួយ ឬចំពោះបុគ្គលិកណាម្នាក់របស់អ្នកធានាដែលកើតចេញពីការបំពេញការងារ។

ង ការបាក់បែកទ្រព្យសម្បត្តិ ដែលឋិតនៅក្រោមការគ្រប់គ្រងតាមផ្លូវច្បាប់របស់អ្នកធានា។

## ផ្នែកទី ៦៖ ការប្លន់យន្តហោះ

មិនមាន

## ផ្នែកទី ៧៖ គ្រោះថ្នាក់ដល់ជីវិត និងពិការភាពអចិន្ត្រៃយ៍

ក អ្នកធានាដែលចូលរួមក្នុងការបើកបរ ឬការចូលរួមក្នុងការប្រឡងប្រជែងវិជ្ជាជីវៈណាមួយ។

ខ អ្នកធានាដែលពាក់ព័ន្ធនឹងការហោះហើរ និងសកម្មភាពក្នុងអាកាស លើកលែងតែការធ្វើដំណើរតាមជើងយន្តហោះដែលបានចុះបញ្ជីយ៉ាងត្រឹមត្រូវ។

គ អ្នកធានាដែលចូលរួមក្នុងទម្រង់ណាមួយនៃការងារដែលធ្វើដោយដៃ។

## ផ្នែកទី ៨៖ សេវា និងជំនួយការវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ ២៤ម៉ោង

ក អ្នកធានាដែលរងរបួសតិចតួច ការដាច់រលាត់ធម្មតា និងអាការៈមិនស្រួលខ្លួនតិចតួចដែលអាចព្យាបាលបាននៅក្នុងស្រុក និងដែលមិននាំទៅដល់ការអាក់ខានក្នុងការធ្វើដំណើររបស់អ្នកធានា។

ខ អ្នកធានាដែលធ្វើដំណើរមិនគោរពតាមការណែនាំរបស់វេជ្ជបណ្ឌិត ឬការធ្វើដំណើរក្នុងការស្វះស្វែងរកការព្យាបាលវេជ្ជសាស្ត្រ។

***កំណត់ចំណាំ**

ឯកសារទាមទារសំណងទាំងអស់ត្រូវបញ្ជូនទៅកាន់ក្រុមហ៊ុនធានារ៉ាប់រងហ្វតេ ក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីបញ្ចប់ការធ្វើដំណើរ។
របាយការណ៍គ្រូពេទ្យ លិខិតបញ្ជាក់អំពីជំងឺ និងវិក្កយបត្រទាំងឡាយត្រូវមានជាចាំបាច់ ដើម្បីទាមទារសំណងរបស់អ្នក។ សូមភ្ជាប់មកជាដាច់ខាតរាល់វិក្កយបត្រ និងបង្កាន់ដៃទទួលប្រាក់។

PJ/TRVK/V2/0311

FORTE
INSURANCE
We build confidence

Traveller's Insurance

# លក្ខណៈពិសេស និងអត្ថប្រយោជន៍ នៃការធានារ៉ាប់រងលើ អ្នកធ្វើដំណើររបស់ ក្រុមហ៊ុនហ្វតេ

## ផ្នែកទី ១៖ អីវ៉ាន់ និងរបស់របរផ្ទាល់ខ្លួន

ក្រុមហ៊ុនហ្វូតតេនឹងសងអ្នកធានាវិញនូវតម្លៃពិត ឬតម្លៃជួសជុល អីវ៉ាន់ វ៉ាលី ឬរបស់របរ ដែលដាក់តាមខ្លួន រួមទាំងរបស់របរ ដែលបានទិញក្នុងអំឡុងពេលធ្វើដំណើរ ដែលការបាត់បង់ ឬការបាក់បែក ត្រូវបានកំណត់ត្រឹម ៣០០ ដុល្លារ ក្នុងរបស់នីមួយៗ ឬមួយគូ ឬមួយសម្រាប់ និងខ្ពស់បំផុតត្រឹម ៩០០ ដុល្លារ លើគ្រឿងអលង្ការ ឧបករណ៍ថតរូបភាព ឬត្រង់ស៊ីស្ទ័រក្នុងគម្រោងពិសេស ( supper plan ) ឬ១៥០ដុល្លារ និង ៤៥០ ដុល្លាររៀងគ្នាចំពោះគម្រោងធម្មតា ( standard plan )។

## ផ្នែកទី ២៖ ការសម្រាកព្យាបាល និងការចំណាយបន្ថែមផ្សេងៗនៅបរទេស

ក្រុមហ៊ុនហ្វូតតេនឹងសងអ្នកធានារ៉ាប់រងវិញនូវ៖

- **ការចំណាយលើការសម្រាកព្យាបាលនៅបរទេស** - រាល់ការចំណាយដ៏សមរម្យលើការសម្រាកព្យាបាលនៅមន្ទីរពេទ្យ ការវះកាត់ ឡានសង្គ្រោះបន្ទាន់ ការថែទាំនៅផ្ទះ និងចំណាយលើការថែទាំផ្សេងៗទៀត ដែលផ្តល់ដោយ ឬចេញវេជ្ជបញ្ជាដោយប្រតិបត្តិករវេជ្ជសាស្ត្រស្របច្បាប់ ដែលការចំណាយនោះកើតមានឡើងនៅក្រៅប្រទេសកម្ពុជា បណ្តាលមកពីការធ្លាក់ខ្លួនឈឺ ឬគ្រោះថ្នាក់ណាមួយលើអ្នកធានារ៉ាប់រង។ ការចំណាយទាំងនោះក៏រួមបញ្ចូលផងដែរលើការព្យាបាលធ្មេញ ប្រសិនបើគ្រោះថ្នាក់នោះធ្វើឱ្យខូចធ្មេញពីកំណើត។
- **ការចំណាយបន្ថែមផ្សេងៗ** - រាល់ការចំណាយដ៏សមរម្យលើការស្នាក់នៅ និងការធ្វើដំណើររបស់អ្នកធានាក្នុងអំឡុងពេលនៃការធានារ៉ាប់រង ដែលលើសពីការចំណាយធម្មតាដោយសារតែអ្នកធានាត្រូវបញ្ចប់ការធ្វើដំណើរមុន ឬក្រោយពេលកំណត់ដោយសារស្ថានភាពនៃជំងឺ និងរបួស។ ចំណាយបន្ថែមទាំងនោះក៏រួមបញ្ចូលទាំងការចំណាយលើការស្នាក់នៅ និងការធ្វើដំណើររបស់សាច់ញាតិម្នាក់ដែលធ្វើដំណើរទៅស្នាក់នៅជាមួយ និងវិលត្រឡប់មកប្រទេសកម្ពុជាវិញជាមួយអ្នកធានា ប្រសិនបើមានការណែនាំជាលាយលក្ខណ៍អក្សរពីប្រតិបត្តិករវេជ្ជសាស្ត្រដែលមើលថែអ្នកធានានោះថាពិតជាចាំបាច់។

## ផ្នែកទី ៣៖ ការខាតបង់ប្រាក់កក់ និងការបង់ថ្លៃលើការលុបចោលការធ្វើដំណើរ

ក្រុមហ៊ុនហ្វូតតេនឹងសងវិញនូវរាល់ការខាតបង់លើប្រាក់កក់ដែលបានបង់សំរាប់ការធ្វើដំណើររបស់អ្នកធានា ឬការទទួលខុសត្រូវរបស់អ្នកធានាដែលមិនអាចទទួលបានវិញពីការលុបចោលការធ្វើដំណើរដែលបណ្តាលមកពីការឈឺ ឬរបួសធ្ងន់នៃអ្នកធានា ឬសាច់ញាតិ និងពីហេតុផលមួយចំនួនដែលហួសពីសមត្ថភាពគ្រប់គ្រងបានរបស់អ្នកធានា ក្រោយពេលប័ណ្ណធានារ៉ាប់រងចូលជាធរមាន និងការបង្ហាញនូវឯកសារច្បាស់លាស់។

## ផ្នែកទី ៤៖ ការបាត់ប្រាក់កាស

ក្រុមហ៊ុនហ្វូតតេនឹងសងអ្នកធានានូវប្រាក់ដែលបាត់ ឬសាច់ប្រាក់ មូលប្បទានប័ត្រ មូលប័ត្រធនាគារ ដែលចោរលួចការទិញលុយ ឬការផ្ញើលុយ និងការបាត់បង់ ចោរលួច ឬការបន្លំការប្រើប្រាស់មូលប្បទានប័ត្រអ្នកធ្វើដំណើរ ឬប័ណ្ណឥណទានដែលអ្នកធានាយកទៅជាមួយ។

## ផ្នែកទី ៥៖ ទំនួលខុសត្រូវផ្ទាល់ខ្លួន

ក្រុមហ៊ុនហ្វូតតេនឹងចេញសងជំនួសអ្នកធានានូវកាតព្វកិច្ចផ្លូវច្បាប់ដែលតម្រូវឱ្យសងក្នុងករណីដែល

ក) បង្ករបួសស្នាម (រួមបញ្ចូលទាំងស្លាប់ ឬឈឺ) ទៅលើអ្នកដទៃ

ខ) ការបាក់បែក ឬការបាត់បង់របស់ទ្រព្យអ្នកដទៃ ដែលបង្កឡើងដោយគ្រោះថ្នាក់ជាយថាហេតុក្នុងពេលធ្វើដំណើរ។ ហ្វូតតេក៏នឹងចេញសងផងដែរលើការចំណាយផ្នែកច្បាប់ និងការចំណាយផ្សេងៗដែលកើតមានឡើងដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនហ្វូតតេ ប្រសិនបើទំនួលខុសត្រូវសរុបរបស់ក្រុមហ៊ុនមិនលើសពីចំនួន ដែលបានបញ្ជាក់ក្នុងគម្រោងនៃកិច្ចសន្យា។

## ផ្នែកទី ៦៖ ការប្លន់យន្តហោះ

ក្រុមហ៊ុនហ្វូតតេនឹងចេញសងដល់អ្នកធានាចំនួន៦០០ ដុល្លារក្នុង១ថ្ងៃរហូតដល់រយៈពេលអតិបរមា៥ ថ្ងៃ ក្នុងគម្រោងពិសេសនិង ៣០០ ដុល្លារក្នុង ១ ថ្ងៃរហូតដល់រយៈពេលអតិបរមា៥ ថ្ងៃក្នុងគម្រោងធម្មតា ក្នុងព្រឹត្តការណ៍នៃការប្លន់យន្តហោះលើសពីរយៈពេល១២ម៉ោងជាប់គ្នា។

## ផ្នែកទី ៧៖ ការគ្រោះថ្នាក់ដល់ជីវិត និងពិការភាពអចិន្ត្រៃយ៍

ក្រុមហ៊ុនហ្វូតតេនឹងចេញសងលើគ្រោះថ្នាក់ដល់ជីវិត ឬពិការភាពជាអចិន្ត្រៃយ៍ ដែលបណ្តាលមកពីការរងរបួសក្នុងរយៈពេល ១២ ខែ ចាប់ពីថ្ងៃកើតមានគ្រោះថ្នាក់ ប្រសិនបើគ្រោះថ្នាក់នោះកើតឡើងក្នុងអំឡុងពេលនៃការធានារ៉ាប់រង។

លទ្ធភាពកម្រិតអតិបរមានៃសំណងនឹងនៅដដែល ទោះជាចំនួនអ្នកដែលធានាលើសពីម្នាក់ក៏ដោយ។

ពិការភាពអចិន្ត្រៃយ៍មានន័យថា

ក ពិការដៃជើងទាំងស្រុង

ខ វិកលចរិតមិនអាចព្យាបាលបាន

គ ពិការភ្នែកម្ខាង ឬទាំងសងខាងដែលមិនអាចជាឡើងវិញ

ឃ ការបាត់ជើង ឬដៃម្ខាង ឬទាំងសងខាង

## ផ្នែកទី ៨៖ សេវា និងជំនួយការវេជ្ជសាស្ត្រ សម្រាប់ការសង្គ្រោះបន្ទាន់ ២៤ ម៉ោង

SOS អន្តរជាតិ (ឬហៅកាត់ SOS) តាមរយៈបណ្តាញសេវា ២៤ ម៉ោងរបស់ខ្លួន នឹងផ្តល់សេវាប្រឹក្សា និងជំនួយតាមទូរស័ព្ទក្នុងករណីបន្ទាន់។

ក្នុងករណីរងរបួស ឬឈឺធ្ងន់ធ្ងរ ដែលតម្រូវឱ្យដឹកជញ្ជូនមកប្រទេសដើមវិញ

- SOS នឹងរៀបចំការដឹកជញ្ជូនជាបន្ទាន់ដោយឡានពេទ្យ ឬមធ្យោបាយផ្សេងទៀតរួមទាំងចាត់ចែងវេជ្ជបណ្ឌិតម្នាក់និង ឬគិលានុបដ្ឋាយិកាម្នាក់ ប្រសិនបើចាំបាច់ដើម្បីអមដំណើរជាមួយអ្នកធានាទៅកាន់មន្ទីរពេទ្យដែលជិត និងសមរម្យបំផុត។
- ប្រសិនបើចាំបាច់ SOS នឹងរៀបចំបន្ថែមទៀតនូវជើងយន្តហោះ សំបុត្រថ្នាក់ធម្មតាដើម្បីបញ្ជូនអ្នកធានាត្រឡប់មកប្រទេសកម្ពុជាវិញ ក្នុងករណីដែលសំបុត្រត្រឡប់មកវិញរបស់អ្នកធានាលែងមានសុពលភាព ឬករួមនឹងការចំណាយបន្ថែមផ្សេងៗលើរថយន្តពេទ្យសម្រាប់ផ្ទេរទៅ និងមកពីព្រលានយន្តហោះ។

### ក្នុងករណីគ្រោះថ្នាក់ដល់ជីវិត

- SOS នឹងរៀបចំធ្វើកោសល្យវិច័យ និងបញ្ជូនសពទៅកាន់អាកាសយានដ្ឋានប្រទេសកម្ពុជា ឬបញ្ចុះនៅបរទេស ប្រសិនបើចំណាយតិចជាងការដឹកជញ្ជូន។

### ករណីលើកលែង

កិច្ចសន្យាធានារ៉ាប់រងនេះមិនធានាលើករណីខាងក្រោមនេះអាចអនុវត្តទៅលើ៖

### គ្រប់ផ្នែកទាំងអស់

ក ផលប៉ះពាល់ដែលកើតចេញពីសង្គ្រាមដែលប្រកាស ឬមិនប្រកាសដឹងជាមុន ឬសកម្មភាពពាក់ព័ន្ធនឹងការឈ្លានពាន ឬសង្គ្រាមស៊ីវិល។

ខ ការបង្ករបួសលើខ្លួនឯងដោយចេតនា ឬការសម្លាប់ខ្លួន ទោះជាបទឧក្រិដ្ឋ ឬមិនឧក្រិដ្ឋ ឬការប៉ុនប៉ងធ្វើបែបនោះ ទោះបីវិកលចរិត ឬមិនមែនក៏ដោយ។

គ ការពរពោះ ការសម្រាលកូន ការរលូតកូន ការរំលូតកូន និងរាល់បញ្ហាពាក់ព័ន្ធស្រដៀងគ្នា លើកលែងតែហេតុការណ៍នោះកើតឡើងដោយចៃដន្យ។

ឃ ការសេពគ្រឿងស្រវឹង គ្រឿងញៀន ឬឱសថដែលគ្មានវេជ្ជបញ្ជាពីប្រតិបត្តិករវេជ្ជសាស្ត្រ ស្របច្បាប់ និងការព្យាបាលពាក់ព័ន្ធនឹងការញៀនថ្នាំ ឬគ្រឿងស្រវឹង។

ង ការទាមទារសំណងដោយផ្ទាល់ ឬដោយប្រយោល ដែលកើតចេញពីផលវិបាកនៃការបំផ្ទុះគ្រាប់បែកបរិមាណូ ចំហាយកម្តៅបរិមាណូ និងការប៉ះពាល់ដោយសារជាតិវិទ្យុសកម្មផ្សេងៗ។

ច ការលើកលែងក្នុងករណីមានការបំផ្លិចបំផ្លាញដោយចេតនា និងអំពើភេរវកម្ម។

## ផ្នែកទី ១៖ អីវ៉ាន់ និងរបស់របរផ្ទាល់ខ្លួន

ក ៣៥ ដុល្លារដំបូង សម្រាប់រាល់ការទាមទារសំណងនីមួយៗ។

ខ លុយ ការទិញដូរលុយ ការផ្ញើលុយ តែម មូលប្បទានប័ត្រធនាគារ មូលប្បទានប័ត្រអ្នកធ្វើដំណើរ ប័ណ្ណឥណទាន សំបុត្រធ្វើដំណើរ ឯកសារ សំណេរ និងមូលប្បទានបត្រទីផ្សារផ្សេងៗទៀត។

គ កែវដាក់ភ្នែក កុំព្យូទ័រយួរដៃ សៀវភៅសរសេរ កុំព្យូទ័រដែលអាចយួរបាន ទូរស័ព្ទ និងម៉ាស៊ីនថតគ្រប់ប្រភេទរបស់របរ ដែលងាយបាក់បែក លើកលែងតែមានភ្លើងឆេះ ឬគ្រោះថ្នាក់ចំពោះអ្នកធ្វើដំណើរ ដែលយករបស់ទាំងនោះទៅតាម។

ឃ ទំនិញធ្វើអាជីវកម្ម ឬគំរូទំនិញ។

ង ការសឹករេចរឹល ឬការខូចជាធម្មតា ការរុះរើ ឬការទ្រុឌទ្រោមរបស់របរមេកានិច ការសម្អាត ការលាបពណ៌ ការជួសជុលឡើងវិញ ដែលបណ្តាលមកពីកត្តាបរិយាកាស ឬអាកាសធាតុ។

ច អីវ៉ាន់ដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់ក្រុមហ៊ុនអាកាសចរណ៍ ឬក្រុមហ៊ុនដឹកជញ្ជូន លើកលែងតែបានរាយការណ៍ ក្នុងរយៈពេល២៤ម៉ោង ហើយមានរបាយការណ៍បញ្ជាក់ពីភាពមិនប្រក្រតីលើរបស់ទ្រព្យពីក្រុមហ៊ុនអាកាសចរណ៍នោះ ឬការបញ្ជាក់ជាលិខិតស្នាម ឬរបាយការណ៍ពីក្រុមហ៊ុនដឹកជញ្ជូន។

ឆ រាល់ការខូចខាត ឬបាត់បង់ដែលមិនបានរាយការណ៍ទៅប៉ូលីសក្នុងរយៈពេល ២៤ម៉ោង និងបានទទួលរបាយការណ៍ពីប៉ូលីស។

ជ ការរឹបអូសដោយអាជ្ញាធរគយ។

## ផ្នែកទី ២៖ ការចំណាយលើការសម្រាកព្យាបាលនៅបរទេស និងចំណាយបន្ថែមផ្សេងៗ

ក ៣៥ ដុល្លារដំបូង សម្រាប់ការទាមទារសំណងនីមួយៗ។

ខ រាល់ការចំណាយលើការព្យាបាលជំងឺ ដែលការវិភាគរោគសញ្ញា ការពិគ្រោះវេជ្ជសាស្ត្រ ឬការចេញវេជ្ជបញ្ជាលើឱសថមានមុនការធ្វើដំណើរ។

គ ការធានាដែលធ្វើដំណើរខុសពីការណែនាំរបស់វេជ្ជបណ្ឌិត ឬក្នុងគោលបំណងស្វែងរកការព្យាបាលវេជ្ជសាស្ត្រ។